N°12
7/140 - Reçu le 5-5-51 -
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

U-45
U.205 — 3-5-51
N-2857



ឆ្នាំទី ១ ផល្គុន លេខ ១២

ព. ស. ២៤៩៣ – គ. ស. ១៩៥០

ទស្សនាវដ្តីអនុមាសផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ **ឈឹម - ក្រសេម**

សំណាក់ការ លេខ ៣៥ អា., វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង

| | | ទំព័រ |
|---|---|---|
| វិចារណកថា | | ៤៤១ |
| ឥទ្ធិបាទ ៤ | ព្រះពោធិវង្ស ហ. តាត | ៤៤៣ |
| លំនាំព្រះអភិធម្ម | ភិក្ខុនារទៈ | ៤៥២ |
| ប្រវត្តិព្រះវិភទ្ទញាណ សោម - ឡុច | | ៤៦០ |
| ក្បួនមេកាព្យ (តចប់) | ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ | ៤៦៤ |
| សេចក្តីសង្កេតអំពីរបៀបគ្រោងការ | សុភមិត្ត | ៤៦៩ |
| បញ្ចតន្ត្រៈ (តមក) សេចក្តីប្រែរបស់ | ភិក្ខុ ប៉ាង - ខាត់ | ៤៧៨ |

| ថ្លៃជាវ | | |
|---|---|---|
| | ១ ឆ្នាំ | ៩៦,០០ |
| | ១ ឆមាស | ៤៨, ០០ |
| | ៣ ត្រីមាស | ២៤, ០០ |
| | ១ក្បាល | ៨, ០០ |

អ្នកអានទាំងឡាយ។ សូមអញ្ជើញចុះឈ្មោះជាវ។

និងបបួលញាតិមិត្តជួយជាវ។

ជីវិតទស្សនាវដ្តីស្ថិតលើលោកអ្នក ៗ

# វិចារណកថា

នាវាមួយៗ មានអ្នកកាន់ការច្រើននាក់គឺ នាយនាវា, អ្នកកាន់ចង្កូត អ្នកកាន់បញ្ជី, អ្នកកាន់គ្រឿងចក្រ, អ្នកធ្វើអាហារ, អ្នកលីសែងជាដើម ដែលកាន់កាប់នាទីដោយឡែកៗ រៀងៗខ្លួន ៗ ជនម្នាក់ៗគប្បីខិតខំបំពេញមុខងាររបស់ខ្លួនឲ្យពេញបរិបូណ៌ មិនត្រូវជ្រួញរវល់នឹងមុខងារអ្នកដទៃ ដោយការគយគន់រំពៃមើលទោសទេ ព្រោះការត្រួតត្រាឬផ្តោលទោសជាភារៈនៃនាយនាវា ៗ នាវាជនគ្រប់គ្នា លុះណាតែបានបំពេញនាទីខ្លួនត្រឹមត្រូវហើយ ទើបសមឈ្មោះថា នាវាជនពេញលក្ខណៈ, សមគួរដល់ការទទួលនូវកិត្តិយស នឹងរង្វាន់ខាន់ទៅគ្រប់ប្រការ ៗ នាវា, កាលបើអ្នកកាន់ការទាំងនោះបានបំពេញកិច្ចរៀងៗខ្លួនល្អហើយ, នឹងអាចប្រព្រឹត្តទៅបានដោយសុវត្ថិភាព ៗ បើនាវាជនណាមួយ ធ្វេសប្រហែសមិនបានបំពេញនាទីខ្លួនឲ្យត្រឹមត្រូវ, នាវាមិនអាចនឹងប្រព្រឹត្តទៅបានដោយប្រពៃទេ មុខជានឹងមានប៉ះទង្គិច ដោយអន្តរាយណាមួយគឺការរអាក់រអួល ស្ទន់ដំណើរឬលិចលង់កណ្ដាលសាគរពុំខាន ៗ

កងសង្គមមួយៗ ដូចនាវាដែរ ៗ ជនម្នាក់ៗ ត្រូវខិតខំបំពេញនាទីរបស់ខ្លួនឲ្យពេញបរិបូណ៌ កុំបណ្ដោយខ្លួនឲ្យជាអ្នករំពៃមើលទោសគេ ៗ ឧបជ្ឈាយ៍ចៅហ្វាយនាយ លោកមាននាទីខាងមើលទោសសិស្សគណអ្នកនៅក្រោមបង្គាប់ដោយមេត្តាចិត្ត ប្រយោជន៍នឹងណែនាំអ្នកទាំងនោះ

ឲ្យមានចរិយា និងសីលធម៌ល្អ ។ ចុះយើងដែលមិនមាននាទីជាឧបជ្ឈាយ៍ ឬចៅហ្វាយនាយ ម្តេចក៏ចូលចិត្តមើលតែទោសគេ ហើយមិនរវល់ដល់ការងារជានាទីរបស់ខ្លួន? ។ ទោសធំគឺការធ្វេសប្រហែសក្នុងករណីយកិច្ចជាមុខងារ ហើយគិតតែរំពៃតមើលទោសគេ ។ ការគយគន់មើលទោសគេ ហើយភ្លេចខ្លួនឈប់មិនបានបំពេញមុខងាររបស់ខ្លួនដែលខ្លួនព្រមទទួលធ្វើ ហើយដែលអ្នកផងបានដឹងត្រូវជឿជាក់សង្ឃឹមថា ខ្លួនព្រមទទួលបំពេញនាទីនោះស្រេចទៅហើយ, នេះលោកហៅថាកុហកខ្លួនឯង ។ កុហកគេ ឈ្មោះថាអាក្រក់មួយចំណែកទៅហើយ, តែការកុហកខ្លួនឯង ឈ្មោះថាអាក្រក់ក្រៃលែងអាក្រក់ទៅទៀត ព្រោះជាទោសនាំបំផ្លិចបំផ្លាញប្រយោជន៍ក្នុងសង្គមទាំងមូល ។ ការមើលទោសគេគ្រាន់តែមើលងាយគេ ឬបន្ទោសគេប៉ុណ្ណោះ មានប្រយោជន៍ដូចម្តេច? បានគ្រាន់តែគេស្អប់ បានគ្រាន់តែគេរករឿងព្យាបាទ ហើយនាំឲ្យខូចសាមគ្គីធម៌ក្នុងសង្គម ព្រមទាំងនាំឲ្យខូចពេលវេលាសម្រាប់បំពេញនាទីរបស់ខ្លួនផង ។ តែយើងចូលចិត្តមើលទោសគេណាស់ មិនចង់មើលទោសខ្លួនឯងទេ បានជាបុរាណលោកពោលថា "ទោសគេតូចសោតសល់មើលយល់ប៉ុនទាំងភ្នំ" ។ ការរំពៃតមើលកំហុសខ្លួនយើង ជាកិច្ចមានប្រយោជន៍សំខាន់ណាស់ ព្រោះអាចនឹងបានដឹងថាខ្លួនយើងខុសត្រង់ណាខ្លះ ហើយនឹងបានកែប្រែខ្លួនឲ្យបានល្អទៅជាអរិយជនឡើង ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌, អ្នកនោះទើបឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន នឹងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

# ឥទ្ធិបាទ ៤

(ដកស្រង់ពីសន្និសីទដែលព្រះពោធិវង្ស ហ. តាត ថ្លែងនៅសាលាបាលីជាន់ខ្ពស់)

អស់លោក អស់អ្នកទាំងឡាយ,

លំដាប់អំពីនេះ ខ្ញុំករុណា អាត្មា សូមនាំយកពុទ្ធភាសិតមួយអន្លើ មកថ្លែងជូនអស់លោក អ្នកទាំងឡាយទុកជាគោលសម្រាប់ពិចារណា ។

កាលមុន ៤ ខែ ព្រះសម្ពុទ្ធជាម្ចាស់នឹងចូលបរិនិព្វាន ព្រះអង្គមានព្រះពុទ្ធដីកាទៅនឹងព្រះអានន្ទថា “ម្នាលអានន្ទ ឥទ្ធិបាទ ៤ យ៉ាង គឺឆន្ទៈ វីរិយៈ ចិត្តៈ នឹងវីមំសា អ្នកណាមួយបានចំរើន បានសន្សំឲ្យមានច្រើនក្នុងខ្លួន អ្នកនោះបើត្រូវការចង់ឲ្យអាយុរបស់ខ្លួនឋិតនៅអស់កប្ប ក៏អាចឋិតនៅបាន” ព្រះពុទ្ធដីកានេះ ព្រះអង្គត្រាស់ចំពោះនឹងព្រះអានន្ទដល់បីដង ជាឱកាសនិមិត្ត បំភ្លឺឲ្យអានន្ទក្រែងចង់និមន្តព្រះអង្គឲ្យគង់នៅតទៅទៀត

ប៉ុន្តែព្រះអានន្ទមិនយល់សោះ ព្រោះក្នុងខណៈនោះមារចូលទៅបិទបាំង
លោកមិនឲ្យមានគំនិតប្រាជ្ញានឹកឃើញអ្វីបាន ទាល់តែព្រះសម្ពុទ្ធជាម្ចាស់
ត្រាស់ឲ្យព្រះអានន្ទចេញទៅខាងក្រៅទៅ, លុះព្រះអានន្ទចេញទៅភ្លាម
មារក៏ចូលមកក្រាបបង្គំទូលព្រះពុទ្ធជាម្ចាស់ ១ រំពេច ថាសូមព្រះអង្គនិមន្ត
ចូលបរិនិព្វានទៅចុះកុំគង់នៅយូរពេក ព្រះអង្គក៏ទទួលនិមន្តមារក្នុងពេល
នោះទៅ ។ តពីពេលនោះមិនយូរប៉ុន្មាន ព្រះអានន្ទក៏ស្មានក្នុងគំនិតយល់
ក្នុងឱកាសនិមិត្តដែលព្រះអង្គទ្រង់ពន្យល់នោះ ទើបត្រឡប់មកក្រាបបង្គំ
ទូលសូមអារាធនា ឲ្យព្រះអង្គគង់នៅអស់កប្ប កុំអាលចូលបរិនិព្វាន ។
ព្រះអង្គតបថា មិនកើតទេ អានន្ទ តថាគតពន្យល់អ្នកដល់ ៣ ដង អ្នកមិន
និមន្តតថាគត ឥឡូវតថាគត ទទួលនិមន្តមាររួចទៅហើយ ថានឹងចូល
បរិនិព្វានក្នុងពេលគិតពីថ្ងៃនេះទៅ ៤ ខែ ។ ព្រះអានន្ទស្តាយណាស់
ខំទទូចនិមន្តព្រះសម្ពុទ្ធជាម្ចាស់ អស់ ៣ ដង ។ ព្រះអង្គទ្រង់ហាមឃាត់ថា
កុំអានន្ទមិនកើតទេ តថាគតទទួលនិមន្តមាររួចទៅហើយ អានន្ទកុំទទូច
ច្រើនដងពេក តែទទូចយ៉ាងនេះហៅថារឹងទទឹង នឹងនាំឲ្យមានទោសដល់
ខ្លួន ។ ព្រះអានន្ទឮដូច្នោះ ក៏ស្ងប់ស្ងៀមមិនហ៊ានទទូចនិមន្តទៅទៀត
ហើយទទួលទុក្ខសោកដោយសេចក្តីអាឡោះអាល័យ ចំពោះអង្គព្រះពុទ្ធ
ជាម្ចាស់ដោយអស់សង្ឃឹមថា ព្រះអង្គនឹងមិនបានគង់នៅតទៅទៀតឡើយ
មុខជាព្រះអង្គនឹងចូលព្រះបរមនិព្វានក្នុង ៤ ខែទៀត ។

សេចក្ដីខាងលើនេះ មានក្នុងមហាបរិនិព្វានសូត្រ ខ្ញុំករុណាអាត្មាបានស្រង់យកមកថ្លែងយ៉ាងសង្ខេបសើរើយកពុទ្ធភាសិតដែលទ្រង់សំដែងអំពីឥទ្ធិបាទ មកធ្វើជាប្រស្នាជូនអស់លោក-អ្នកទាំងឡាយ សូមឲ្យគិតពិចារណាមើល ។

១ – ធម៌ដែលព្រះអង្គបានសំដែងហើយមានចំនួនច្រើនណាស់ ហេតុដូចម្ដេច បានជាព្រះសម្ពុទ្ធជាម្ចាស់ លើកយកតែឥទ្ធិបាទ ១ ប៉ុណ្ណោះ មកសំដែងសរសើរថាអាចញុំាងអ្នកដែលបានចំរើន ឲ្យសម្រេចដូចសេចក្ដីប្រាថ្នា ?

២ – ដែលព្រះអង្គសំដែងរឿងនេះចំពោះព្រះអានន្ទ មានទំនងដូចជាព្រះអង្គចង់ឲ្យព្រះអានន្ទនិមន្តព្រះអង្គឲ្យគង់នៅបានយូរតទៅទៀត បើដូច្នេះហាក់ដូចជាព្រះអង្គមានបំណងនឹងគង់នៅតទៅទៀតឬ?

៣ – ព្រះពុទ្ធជាម្ចាស់ទ្រង់ជ្រាបធម៌ឥទ្ធិបាទនេះសព្វគ្រប់ហើយ បានចំរើនឲ្យកើតមានក្នុងព្រះអង្គរួចហើយ បើព្រះអង្គចង់ឲ្យបានគង់នៅតទៅទៀត ហេតុដូចម្ដេចក៏ធម៌ឥទ្ធិបាទដែលមានស្រាប់ហើយ ក៏មិនជួយបន្តអាយុរបស់ព្រះអង្គឲ្យបានឋិតថេរអស់កប្បទៅ? ។

៤ – គេតែងចូលចិត្តថា ក្នុងពេលនោះទាស់លើព្រះអានន្ទមិននិមន្តព្រះពុទ្ធជាម្ចាស់ឲ្យគង់នៅ ប្រសិនបើបាននិមន្ត មុខជាព្រះពុទ្ធជាម្ចាស់នឹងបានគង់នៅរហូតដល់សព្វថ្ងៃនេះ ។ មកពីព្រះអានន្ទមិនបាននិមន្តមុន

ទៅបានឯមារតំបាបចូលទៅនិមន្តមុន បានជាព្រះចូលបរិនិព្វាន, ដូច្នេះពិតមែនឬដូចម្ដេច ?

ប្រស្នាខាងលើទាំង ៤ ខនេះ ជាប្រស្នាទ្រុបទ្រុលណាស់ ខ្ញុំករុណាអាត្មាមិនបានដោះស្រាយរឿងនេះឲ្យពិស្ដារទេ សូមសរុបសេចក្ដីឲ្យខ្លីចុះតែម្ដង; ព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គជាព្រះពុទ្ធ មានប្រាជ្ញាញាណជ្រាបកិច្ចការអ្វីឥតសល់ មានព្រះទ័យស្អាតបរិសុទ្ធ ឥតទាក់ទាមដោយឧបក្កិលេសធម៌ណាមួយ ដែលទ្រង់សំដែងសរសើរធម៌ឥទ្ធិបាទចំពោះនឹងព្រះអានន្ទដូចខាងលើនេះគឺ:

១ – មិនមែនព្រះអង្គចង់ព្រាញឲ្យរស់នៅយូរទៅទៀតទេ មកពីព្រះអង្គឥតជំពាក់ព្រះទ័យនឹងអ្វីឡើយ ត្រង់ស្លាប់និងរស់ព្រះអង្គមិនស្អប់មិនស្រឡាញ់ទេ ។

២ – បើទុកជាព្រះអានន្ទនិមន្តមុនមារក្ដី មារមិនបាននិមន្តក្ដី ក៏គង់តែព្រះអង្គចូលបរិនិព្វាន ព្រោះអាយុសង្ខាររបស់ព្រះអង្គដល់កាលកំណត់ត្រឹមប៉ុណ្ណោះហើយ ។

៣ – ដែលព្រះអង្គលើកយកធម៌ឥទ្ធិបាទមកសំដែងចំពោះព្រះអានន្ទក្នុងពេលនោះ ដោយទ្រង់យល់ឃើញថាធម៌ឥទ្ធិបាទនោះ ជាធម៌មានឥទ្ធានុភាព អាចនឹងធ្វើឲ្យសម្រេចដូចប្រាថ្នាដល់អ្នកដែលបានចំរើនដែលបានបំពេញដោយគ្រប់គ្រាន់ ដូចព្រះពុទ្ធដីកាថា អ្នកដែលបានចំរើន

ឥទ្ធិបាទ បើប្រាថ្នានឹងឲ្យអាយុរបស់ខ្លួនឋិតនៅអស់កប្បក៏អាចឋិតនៅបាន ដូចប្រាថ្នា ។

ព្រះពុទ្ធដីកាខាងលើនេះ ខ្ញុំករុណា អាត្មា បានពិនិត្យពិចារណាហើយ ឃើញថាពិតមែនណាស់ ព្រោះអាយុនៃមនុស្សទាំងឡាយមានកំណត់ត្រឹមប៉ុណ្ណោះខ្លះ ប៉ុណ្ណោះខ្លះ ដោយអំណាចនៃកុសលនិងអកុសលជាអំពើរបស់ខ្លួនបានកម្រិតទុក ប៉ុន្តែមនុស្សទាំងនោះពុំអាចនឹងរក្សាអាយុរបស់ខ្លួនឲ្យឋិតនៅដល់កម្រិត ក៏អស់អាយុមុនកម្រិតនោះទៅ ។ កម្រិតអាយុនោះហៅថាអាយុកប្ប។ នេះហើយដែលព្រះពុទ្ធជាម្ចាស់ត្រាស់ថា អ្នកណាចង់ឲ្យអាយុខ្លួនឋិតនៅអស់កប្ប គឺអាយុកប្ប (កម្រិតអាយុ) ត្រូវខំចំរើនឥទ្ធិបាទទាំងបួន ។ នេះមានអំណាចអាចនឹងរក្សាអាយុនោះឲ្យឋិតនៅតាមប្រាថ្នាបាន ។

សូមអធិប្បាយយ៉ាងសង្ខេប: អ្នកដែលចម្រើនឥទ្ធិបាទទាំង ៤ បើចង់រស់នៅអស់កប្ប អាចឋិតនៅបាននោះដូចម្តេច? អ្នកដែលស្រឡាញ់អាយុជីវិតចង់ឲ្យរស់នៅ ហៅថាមានឆន្ទៈ លុះមានឆន្ទៈគឺសេចក្តីស្រឡាញ់ហើយ បានព្យាយាមរក្សាឥរិយាបថឲ្យស្មើមិនឲ្យមានហេតុកើតឡើង ព្រោះឥរិយាបថ; អំពើណា, ហេតុណា, អ្វីមួយ ដែលជាគ្រឿងនាំឲ្យទើសទាស់ ដល់ការប្រព្រឹត្តទៅស្រួលនៃអាយុជីវិត ក៏ព្យាយាមលះបង់ចេញ, អ្វីមួយដែលនាំឲ្យស្រួលដល់ការបន្តនៃអាយុជីវិត ក៏ព្យាយាម

ប្រព្រឹត្តទៅ, ព្យាយាមដូច្នេះហៅថាវីរិយៈ; ការគិតមើល ពិនិត្យមើល ក្នុងការប្រព្រឹត្តិទៅនៃអាយុ រាល់ពេលរាល់វេលា ឥតមានធ្វេសប្រហែស ពេលស្រួលក៏ដឹង ពេលមិនស្រួលក៏ដឹង ដូច្នេះហៅថាចិត្តៈ; ប្រាជ្ញា ពិចារណារកហេតុដែលស្រួលនឹងមិនស្រួលនោះ ឃើញច្បាស់ថា មិនស្រួលមកពីអ្វី ក៏លះបង់ចោលភ្លាម, ស្រួលមកពីអ្វី ក៏ធ្វើភ្លាម, ដូច្នេះហៅថាវីមំសា ។

សេចក្ដីត្រង់នេះ, ខ្ញុំករុណា, អាត្មា យល់ថាព្រះពុទ្ធជាម្ចាស់ មិនសំដែងចំពោះតែអាយុជីវិតរបស់មនុស្សទេឡើយ គឺព្រះអង្គសំដែងសំដៅចំពោះអាយុនៃដំណើរការគ្រប់យ៉ាងព្រោះពាក្យថាអាយុនេះ ជាភាសាបាលី ប្រែថា "ធម្មជាតជាគ្រឿងចំរើននៃសម្បយុត្តធម៌" ប្រែថា "ប្រព្រឹត្តទៅមុខ" ប្រែថា "សេចក្ដីចំរើន" បានសេចក្ដីថា ចំរើនឡើង ឬចំរើនទៅមុខ ឬថា រស់នៅមិនស្លាប់ ។ ពាក្យថាអាយុនេះគេអាចនិយាយបានច្រើនយ៉ាង:

១– អាយុសាលារៀន: បើអ្នកកាន់កាប់សាលា មិនមានឥទ្ធិបាទទាំង៤ទេ, អាយុសាលានោះនឹងមិនឋិតនៅតទៅមុខបានឡើយ គឺថាសាលានោះត្រូវបិទទ្វារចោល;

២– អាយុនៃសមាគម: បើអ្នកកាន់កាប់សមាគមនីមួយៗ មិនមានឥទ្ធិបាទទាំង ៤ ក្នុងខ្លួនទេ, អាយុនៃសមាគមនោះៗ នឹងមិនឋិតនៅតទៅទៀតបានឡើយ គឺថាសមាគមនោះត្រូវរលាយបាត់ទៅវិញ ;

៣ – អាយុនៃព្រះពុទ្ធសាសនា : បើអ្នកកាន់ព្រះពុទ្ធសាសនាទាំងបព្វជិតទាំងគ្រហស្ថមិនរវល់នឹងព្រះពុទ្ធសាសនាដោយមិនមានធម៌ឥទ្ធិបាទទាំង ៤ ក្នុងខ្លួនទេ គឺគ្មានសេចក្ដីស្រឡាញ់ មិនយកចិត្តទុកដាក់ឥតមានគំនិត ព្រមទាំងគ្មានប្រាជ្ញាថែមទៀត, នោះអាយុនៃព្រះពុទ្ធ-សាសនានឹងចំរើនទៅមុខមិនបានឡើយ គឺថាព្រះពុទ្ធសាសនានោះត្រូវថយថោកសាបរលាបចុះទៅដោយលំដាប់ ៗ

កិច្ចការរបស់មនុស្សក្នុងលោកគប់ចំនួនពុំអស់ ក៏សុទ្ធតែមានអាយុដូចគ្នាទាំងអស់ គឺអាយុនៃកសិកម្ម, អាយុពាណិជ្ជកម្មជាដើម ៗ អាយុនៃការងារនោះ ៗ ដែលត្រូវចំរើន ឬត្រូវថយចុះ ក៏ស្រេចហើយតែអ្នកកាន់កាប់, អ្នកប្រកប មានឥទ្ធិបាទទាំង ៤ ឬ មិនមាន ដូចទំនងសេចក្ដីដែលបានអធិប្បាយរួចមកហើយ ៗ

សេចក្ដីខាងលើនេះជាមតិរបស់ខ្ញុំករុណា, អាត្មា ដែលបានពិចារ-ណាមើលតាមទំនងនៃព្រះពុទ្ធដីកា ៗ មិនតែប៉ុណ្ណោះឡើយ ខ្ញុំករុណាអាត្មា យល់ថាព្រះពុទ្ធជាម្ចាស់ដែលសំដែងចំពោះនឹងព្រះអានន្ទក្នុងពេលមុនចូលបរិនិព្វាន អំពីឥទ្ធិបាទទាំង ៤ យ៉ាងនោះ ដើម្បីឲ្យពួកពុទ្ធ-បរិស័ទទាំងបព្វជិតទាំងគ្រហស្ថ ខំប្រឹងបំពេញឥទ្ធិបាទទាំង ៤ យ៉ាងកុំបោះបង់ឡើយ ក្នុងពេលដែលមានបំណងចង់ឲ្យបានសម្រេចផល

ប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ឬ ក្នុងបរលោក, ក្នុងលោកិយ ឬក្នុងលោកុត្តរ ឥទ្ធិបាទទាំង ៤ យ៉ាងអាចឲ្យសម្រេចផលតាមបំណងជាប្រាកដ ។

ធម៌ឥទ្ធិបាទនេះ មិនចាំបាច់អធិប្បាយឲ្យពិស្តារវែងឆ្ងាយទៅប៉ុន្មានឡើយ គ្រាន់តែប្រែឈ្មោះធម៌ឥទ្ធិបាទជាភាសាខ្មែរយើងឲ្យស្តាប់បាន ក៏អាចចូលចិត្តថាជាធម៌ជួយផ្តល់ឲ្យសម្រេចកិច្ចការគ្រប់យ៉ាងបាន ។

ឥទ្ធិបាទៈ កាត់ចេញជា ២ បទគឺឥទ្ធិ ១ បាទៈ ១, ឥទ្ធិប្រែថា ឫទ្ធិ ក៏បាន ប្រែថាកិរិយាសម្រេចក៏បាន, បាទៈ ប្រែថាទីតាំងទីដំកល់, គ្រឿងទល់ទ្រ ឬប្រែថា ជើងក៏បាន ។ រួមគ្នាទាំងពីរបទ ទៅជាមួយបទ ថា ឥទ្ធិបាទៈ ប្រែរួមគ្នាថា (ធម៌) ជាទីតាំងនៃឫទ្ធិ ឬថា ជាទីតាំងនៃកិរិយាសម្រេច ពុំនោះ ប្រែថា (ធម៌) ជាជើងសម្រាប់ដើរទៅកាន់សេចក្តីសម្រេច រួមសេចក្តីថា (ធម៌) សម្រាប់ដឹកនាំមនុស្សដែលប្រកបកិច្ចការគ្រប់យ៉ាង ឲ្យបានសម្រេចតាមប្រាថ្នា ។ ឥទ្ធិបាទនោះមាន ៤ យ៉ាងគឺ ឆន្ទៈ សេចក្តីប្រាថ្នា សេចក្តីស្រឡាញ់ពេញចិត្ត ១, វីរិយៈ សេចក្តីព្យាយាមប្រឹងប្រែង ១ ចិត្តៈ ចេះគិតលៃលកមិនធ្វេសប្រហែស ១, វីមំសា ពិចារណាឲ្យឃើញហេតុផលច្បាស់លាស់ ១ ។

### សេចក្តីអធិប្បាយៈ

មនុស្សក្នុងលោកសន្និវាសនេះ ដែលបានប្រកបកិច្ចការគ្រប់យ៉ាង តាមឋានៈរបស់ខ្លួន ហើយបានសម្រេចតាមប្រាថ្នា ក៏អាស្រ័យនឹងមាន

ឥទ្ធិបាទក្នុងខ្លួន បើមិនមានឥទ្ធិបាទក្នុងខ្លួនទេ កិច្ចការនោះ ៗ ក៏ពុំបានសម្រេចឡើយ ។ សេចក្ដីនេះពិតមែន សូម្បីព្រះសម្ពុទ្ធជាម្ចាស់ជាកំពូលនៃអ្នកប្រាជ្ញ កាលទ្រង់បំពេញពុទ្ធការកធម៌ ដោយបំណងនឹងឲ្យបានត្រាស់ជាព្រះពុទ្ធ ក៏គង់ព្រះអង្គបានតាំងព្រះទ័យយកធម៌ឥទ្ធិបាទទាំង ៤ ទុកជាប្រមុខ មិនដែលបោះបង់ឡើយ ទើបព្រះអង្គបានត្រាស់ដូចប្រាថ្នា ។ សាវ័ករបស់ព្រះអង្គជាន់ខ្ពស់ នឹងជាន់ទាបជាលំដាប់ចុះមក ដែលបានដំកល់នៅក្នុងឋានៈខ្ពស់នឹងទាបដោយឧបនិស្ស័យធម៌ជួយអប់រំ ក៏អាស្រ័យនឹងធម៌ឥទ្ធិបាទនេះដែរ ។

ក្នុងបច្ចុប្បន្នសព្វថ្ងៃនេះ មនុស្សក្នុងលោកដែលបានបំពេញមុខការរបស់ខ្លួនផ្សេងៗ តាមឋានៈរបស់ខ្លួនដូចពួកគ្រហស្ថ ខ្លះប្រកបខាងកសិកម្ម គឺធ្វើស្រែចំការច្បារដំណាំ, ខ្លះខាងពាណិជ្ជកម្ម គឺការជួញលក់ចេញទិញចូល, ខ្លះរៀនអក្សរសាស្ត្រ នឹងវិទ្យាសាស្ត្រជាដើម ខ្លះធ្វើជាមន្ត្រីកាន់កាប់ការរាជការរបស់រដ្ឋហៅថាអ្នករាជការ, ខ្លះរួបរួមគ្នាធ្វើជាសមាគមខាងផ្លូវជំនួញ ដើម្បីយកកម្រៃផល ខ្លះរួបរួមគ្នាធ្វើជាសមាគមសម្រាប់សង្គ្រោះប្រជាជាតិ សង្គ្រោះប្រទេស សង្គ្រោះព្រះពុទ្ធសាសនា ឥតមានយកកម្រៃចំណេញអ្វីឡើយ ; កិច្ចការមានប៉ុណ្ណោះជាដើម ក៏តោងអាស្រ័យនឹងឥទ្ធិបាទទាំង ៤ យ៉ាងនោះដែរ ទើបសម្រេចតាមប្រាថ្នា ។

# សំណាំព្រះអភិធម្ម (តនិងចប់)

៤ – ភាវរូប នោះគឺ ឥត្ថីភាពនិងបុរិសភាព; ៥ – ហទយរូប គឺដួងចិត្ត; ៦ – ជីវិតរូប គឺការរស់នៅ; ៧ – អាហាររូប គឺអាហារដែលគេបរិភោគ; ៨ – បរិច្ឆេទរូប គឺអាកាសធាតុ; ៩ – វិញ្ញត្តិរូប គឺការធ្វើឲ្យអ្នកដទៃបានដឹងដោយកាយ (កាយវិញ្ញត្តិ) ដោយវាចា (វចីវិញ្ញត្តិ); ១០ – វិការរូបបានដល់ លហុតា មុទុតា កម្មញ្ញតា និងវិញ្ញត្តិទាំង ២ ផង; ១១ – លក្ខណរូប គឺរូបធម៌ដែលមានលក្ខណៈ គឺការកើតស្លាប់ជាហេតុដោយកាល បានដល់ ឧបច្ច័យ (កើតក្នុងខណៈបដិសន្ធិ) សន្តតិ (ចំរើនជាដំណតគ្នា) ជរតា (ខណៈតាំងនៅក្នុងរវាងកើតនិងស្លាប់) និងអនិច្ចតា (រូបដែលរលត់) ។ ត្រង់នេះ ជាតិរូបគឺឧបច្ច័យនិងសន្តតិ ។

ដូច្នេះ គុណសម្បត្តិ ទាំង ១១ នេះ បើពោលដោយពិស្តារមានដល់ទៅ ២៨ ។

ភូតរូបទាំង ៤ ជាឯកភាពសំខាន់នៃរូបវត្ថុ គឺជាកំឡាំងដែលជាប់ទាក់ទងជាបច្ច័យនឹងគ្នា ភូតរូបនីមួយៗ អាចមានភាគច្រើនជាងភូតរូបដទៃ ដូចជាបឋវីធាតុមានច្រើនក្នុងដី អាបោធាតុមានច្រើនក្នុងទឹក តេជោធាតុមានច្រើនក្នុងភ្លើង និងវាយោធាតុ មានច្រើនក្នុងខ្យល់ ។

ក្នុងបុរាណសម័យ អ្នកប្រាជ្ញតេណ្ឋ ជឿថាមានបរមាណូចែករលែកមិនបាន ព្រះពុទ្ធបានកំចាយញែកបរមាណូដែលថាចែករលែកមិនបាននោះហើយប្រកាសថា គ្រាន់តែជាធាតុកម្មនៃកំលាំងដោយឡែកជាបច្ច័យទាក់ទងគ្នាប៉ុណ្ណោះទ្រង់ហៅថាបរមត្ថបុក្ខតរូប ។

បរមត្ថទាំងនោះ គឺ បឋវី អាបោ តេជោនឹងវាយោ តែកុំយល់ថាធាតុទាំងនេះជាដីទឹកភ្លើងនិងខ្យល់ឲ្យសោះ ។ **បឋវី** ប្រែថាធាតុដែលខះដែលរឹង ធាតុរឹងនៃវត្ថុ បើគ្មានធាតុនេះ វត្ថុទាំងឡាយមិនអាចតាំងនៅក្នុងអាកាសបានទេ, ធាតុនេះមានសភាវៈរឹងៗ ឬទន់ៗ ជាលក្ខណៈ, គេនឹងយល់ថាបឋវីធាតុមានក្នុងដីទឹកភ្លើងនិងខ្យល់ ឧបមាដូចទឹកស្រទាប់ខាងលើមានទឹកស្រទាប់ខាងក្រោមជាគ្រឿងទ្រ គឺបឋវីធាតុនេះឯង ដែលលាយក្នុងវាយោធាតុបង្កើតនូវការធាក់ច្រានឡើង ។ **អាបោ** ជាធាតុភ្ជាប់ ខុសគ្នាពីបឋវីធាតុ ធាតុនេះពាល់មិនបានជាធាតុសំរាប់ភ្ជាប់ នូវអណូកត់ពាយឲ្យកើតជាដុំឡើង ។ **តេជោ** ជាធាតុនៃសភាពក្ដៅ ត្រជាក់ជាសភាពមួយនៃតេជោធាតុដែរ ត្រជាក់នឹងក្ដៅរបបពាលក្នុងតេជោ ព្រោះមានអានុភាពផ្សាយនូវរូបវត្ថុ ឬជីវិតិន្ទ្រិយ ។ ការដែលតាំងនៅ ឬ ប្រេះធ្លាយទៅក៏មកតែពីតេជោធាតុនេះឯង ។ **វាយោ** ជាចលនធាតុ, ធាតុនេះជាហេតុនាំឲ្យមានការកំរើក, ចលនធម៌ទុកដូចជាកំឡាំងនឹងមេបង្កើតចណ្ហធាតុ "ធាតុ

ទាំងពីរគឺចលនៈ និងឧណ្ហៈដែលមានក្នុងរូបធម៌ ដូចគ្នានឹងវិញ្ញាណ ហើយនឹងកម្មក្នុងនាមធម៌" ។

មហាភូតរូបទាំង ៤ នេះតែងរួមជានិច្ចជាមួយនឹងកំឡាំង ៤ នៃមហា-ភូតរូបនោះគឺ ពណ៌ ក្លិន រសនឹងចំហាយ ។

ដូច្នេះ តាមព្រះពុទ្ធសាសនា រូបប្រកបដោយកំឡាំងនឹងគុណ-សម្បត្តិដែលប្រែប្រួលជានិច្ច ។

## និព្វាន

បរមត្ថទី ៤ ដែលមានសំដែងក្នុងអភិធម្ម គឺ និព្វានដ៏ជាទីបំណង នៃអ្នកកាន់ព្រះពុទ្ធសាសនា ។ និព្វានពុំមែនជាព្រហ្មាត្ម័នទេគឺជាសភាវៈ លោកុត្តរដែលសម្រេចបានដោយបញ្ញាញាណខ្លួនឯង ។

និព្វាន ប្រែថា "ការចេញចាកចោលនូវសេចក្តីស្រេកឃ្លានដែល ហៅថាតណ្ហា" មាន ២ យ៉ាងគឺ និព្វានដែលព្រះអរហន្តបានចែងច្បាស់ ក្នុងជាតិនេះឯងតែនៅមានខន្ធនៅឡើយហៅថា សឧបាទិសេសនិព្វាន-ធាតុ ។ និព្វានដែលព្រះអរហន្តបានសំរេចក្រោយដែលរំលាយខន្ធទៅ ឈ្មោះថា អនុបាទិសេសនិព្វានធាតុ ។

វិសុទ្ធិសំរាប់ទៅកាន់ព្រះនិព្វានមាន ៧ ថ្នាក់ គឺ

១) សីលវិសុទ្ធិជាថ្នាក់ទី ១ មាន ៤ យ៉ាង ៖

ក) បាដិមោក្ខសំវរសីល សីលដែលទាក់ទងដល់សិក្ខាបទសំខាន់ៗ

ខ) ឥន្ទ្រិយសំវរសីល សីលដែលទាក់ទងដល់ការសំរួមឥន្ទ្រិយ;

គ) អាជីវបារិសុទ្ធិសីល សីលដែលទាក់ទងដល់ការចិញ្ចឹមជីវិតដោយបរិសុទ្ធិ;

ឃ) បច្ចយសន្និស្សិតសីល សីលដែលទាក់ទងដល់ការប្រើប្រាស់នូវបច្ច័យដែលត្រូវការ ៗ វិសុទ្ធិទី ១ នេះជាសម្មាកម្មន្ត ៗ

២) វិសុទ្ធិទី ២ គឺ សមាធិ (ចិត្តវិសុទ្ធិ) យោគាវចរ ជ្រើសរើសនូវអង្គណាមួយនៃកម្មដ្ឋាន ទាំង ៤០ ដែលសមដល់ចរិតរបស់ខ្លួន ហើយបរិកម្មនូវអង្គនោះលុះត្រាតែមូលអារម្មណ៍ ចុះស៊ប់គង់បំណុចតែមួយ ៗ

កម្មដ្ឋានទាំង ៤០ នោះគឺ:

១) កសិណ ១០ = បថវីកសិណ អាបោកសិណ តេជោកសិណ វាយោកសិណ នីលកសិណ បីតកសិណ លោហិតកសិណ ឱទាតកសិណ អាកាសកសិណ និង អាលោកកសិណ ៗ

២) អសុភ ១០ = ឧទ្ធុមាតក វិនីលក វិបុព្វក វិច្ឆិទ្ទក វិក្ខាយិតក វិក្ខិត្តក ហតវិក្ខិត្តក លោហិតក បុលុវក និង អដ្ឋិក ៗ

៣) អនុស្សតិ ១០ = ពុទ្ធានុស្សតិ ធម្មានុស្សតិ សំឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ ឧបសមានុស្សតិ មរណានុស្សតិ កាយគតាសតិ និងអានាបានស្សតិ ៗ

៤) អប្បមញ្ញា ឬព្រហ្មវិហារ ៤ = មេត្តា ករុណា មុទិតា ឧបេក្ខា

៥) អាហារេបដិកូលសញ្ញា ១ គឺការពិចារណានូវធម្មជាតិ បដិកូលរបស់អាហារដែលខ្លួនបរិភោគ ។

៦) ធាតុវវដ្ឋាន ១ – គឺការពិចារណានូវធាតុទាំង ៤

៧) អរូបដ្ឋាន ៤ – គឺ អាកាសានញ្ចាយតន វិញ្ញាណញ្ចាយតន អាកិញ្ចញ្ញាយតន និងនេវសញ្ញានាសញ្ញាយតន ។

កម្មដ្ឋានទាំង ៤០ នេះមានផ្សេងៗ គ្នា ទៅតាមចរិតនិងនិស្ស័យនៃអ្នកបំរើនកម្មដ្ឋាន ដែលចែកចេញជា ៦ ពួកទៅទៀត គឺ:

១ – អ្នកដែលក្រាស់ដោយរាគចរិត; ២ – អ្នកដែលប្រកបដោយទោសចរិត; ៣ – អ្នកដែលប្រកបដោយមោហចរិត; ៤ – អ្នកដែលប្រកបដោយសទ្ធាចរិត; ៥ – អ្នកដែលប្រកបដោយពុទ្ធិចរិត; ៦ – អ្នកដែលប្រកបដោយវិតក្កចរិត ។ អសុភ ១០ និងកាយគតាសតិជាទីសប្បាយនៃបុគ្គលជារាគចរិត ។ ព្រហ្មវិហារ ៤ និងវណ្ណកសិណទាំង ៤ ជាទីសប្បាយនៃអ្នកជាទោសចរិត ។ អានាបានស្សតិ ជាទីសប្បាយនៃអ្នកជាវិតក្កចរិត ។ អនុស្សតិ ៦ ខាងដើមសមដល់អ្នកជាសទ្ធាចរិត ។ មរណានុស្សតិ ឧបសមានុស្សតិ អាហារេបដិកូលសញ្ញា និងចតុធាតុវវដ្ឋាន គួរដល់អ្នកជាពុទ្ធិចរិត ។

កម្មដ្ឋានដទៃគឺពុទ្ធានុស្សតិ មេត្តា កាយគតាសតិ និងមរណានុស្សតិ ដោយចំពោះជាទីសប្បាយនៃបុគ្គលប្រកបដោយចរិតទាំងពួង ។

អ្នកដែលពិចារណានូវកម្មដ្ឋាន អង្គណាមួយ ហើយចំរើនសមាធិរហូតដល់សំរេចឈាន ដោយការកំចាត់មួយគ្រាមួយខណៈនូវនីវរណ-ធម៌ទាំង ៥ មានចិត្តថាដូចកញ្ចក់ ដែលអាចឆ្លុះនូវស្រមោលនៃសភាវៈទាំងឡាយតាមសភាពពិតបាន ។

៣ – ទិដ្ឋិវិសុទ្ធិ ជាវិសុទ្ធិ ទី ៣ ជាញាណដែលអាចឲ្យមើលនូវសភាវៈ ទាំងឡាយតាមសេចក្តីពិត ។

ចិត្តចុះស៊ប់គង់អារម្មណ៍តែមួយហើយ ព្រះយោគាវចរពិចារណានូវអត្តភាពរបស់ខ្លួនដោយល្អិតល្អន់ ឃើញថាខ្លួនលោកនោះ មិនគឺអ្វីក្រៅពីការផ្សំផ្គុំនាមនឹងរូបចូលគ្នាទេ នាមជាចេតនាកម្ម ដែលកើតឡើងព្រោះអារម្មណ៍មកប៉ះនឹងបសាទ, ឯរូបជាកំឡាំងនឹងគុណសម្បត្តិដែលប្រកាសចេញទៅជាធាតុក្លូក ផ្សេងៗ ជាអនេកប្បការ ។

កាលបានយល់ច្បាស់នូវជីវិតតាមសេចក្តីពិតហើយ រដោះផុតពីការសំគាល់ថាមានធាតុទៀងក្នុងនាមរូប, ព្រះយោគាវចរ តាំងត្រិះរិះរកហេតុនៃ "អត្តា" ។ លោកក៏បែងច្បាស់ថា: អវិជ្ជាជាបច្ច័យឲ្យកើតសំខារ សំខារជាបច្ច័យឲ្យកើតវិញ្ញាណ វិញ្ញាណជាបច្ច័យឲ្យកើតនាមរូប នាមរូបជាបច្ច័យឲ្យកើតសឡាយតនៈ សឡាយតនៈជាបច្ច័យឲ្យកើតផស្សៈ ផស្សៈជាបច្ច័យឲ្យកើតវេទនា វេទនាជាបច្ច័យឲ្យកើតតណ្ហា តណ្ហាជាបច្ច័យឲ្យកើតឧបាទាន ឧបាទានជាបច្ច័យឲ្យកើតភព ភពជាបច្ច័យឲ្យ

កើតជាតិ ជាតិជាបច្ច័យឲ្យកើតជរាព្យាធិនិងមរណៈ ។ សំខាររលត់ព្រោះរលត់អវិជ្ជា វិញ្ញាណរលត់ព្រោះរលត់សំខារ នាមរូបរលត់ព្រោះរលត់វិញ្ញាណ សឡាយតនៈរលត់ព្រោះរលត់នាមរូប ផស្សៈរលត់ព្រោះរលត់សឡាយតនៈ វេទនារលត់ព្រោះរលត់ផស្សៈ តណ្ហារលត់ព្រោះរលត់វេទនា ឧបាទានរលត់ព្រោះរលត់តណ្ហា ភពរលត់ព្រោះរលត់ឧបាទាន ជាតិរលត់ព្រោះរលត់ភព ជរាព្យាធិមរណៈរលត់ព្រោះរលត់ជាតិ ។

ព្រះយោគាវចរថ្លែងច្បាស់ថា អត្តភាពនោះមានហេតុជាបច្ច័យ, ដូច្នេះ កម្មអតីតជាបច្ច័យឲ្យកើតកម្មបច្ចុប្បន្ន កម្មបច្ចុប្បន្នឲ្យកើតកម្មអនាគត ។ កាលពិចារណាដូច្នេះហើយ លោកកាច់កំចាត់បង់នូវសេចក្ដីសង្ស័យក្នុងអតីត ក្នុងបច្ចុប្បន្ន និងក្នុងអនាគតបានជ្រះស្រឡះ ត្រង់នេះឈ្មោះថាកង្ខាវិតរណវិសុទ្ធិ ៤ ។ លំដាប់តទៅ លោកពិចារណាឃើញថា សង្ខារៈទាំងឡាយជា អនិច្ចំ ទុក្ខំ និងអនត្តា ។

កាលចុះស៊ប់ក្នុងសមាធិបែបនោះហើយ លោកនឹងបានឃើញថ្ងៃណាមួយនូវឱភាសចេញពីខ្លួនលោកមកហើយកើតបីតិ បស្សទ្ធិ អធិមោក្ខ បគ្គហៈ សុខ ញាណ សតិ ឧបេក្ខានិងនិកន្តិ ។ ការជ្រះថ្លាក្នុងចិត្តកាន់តែចំរើនឡើង, អារម្មណ៍របស់លោកក៏មូលស្នុងល្អ, ឯវិបស្សនាញាណក៏កាន់តែមុតក្រៃលែងឡើង ។ ដោយលុះទៅតាមសេចក្ដីយល់ខុស

ថាខ្លួនបានដល់មគ្គវិសុទ្ធិ ព្រោះតែការសង្កេតឃើញនូវទោស, ព្រះយោ-
គាវចរក៏ត្រាញទៅកន្លងសភាពនៃចិត្តបែបនោះ ។ តែតមកមិនយូរប៉ុន្មាន
លោកដឹងថា និមិត្តទាំងនោះជាឧបក្កិលេសនៃវិបស្សនាញាណពុំមែនជា
មគ្គទៅកាន់វិសុទ្ធិទេ, ទើបលោកសំគាល់នូវមគ្គនិងអមគ្គ នេះទុកជា
មគ្គាមគ្គញាណទស្សនវិសុទ្ធិ ជាវិសុទ្ធិទី ៥ ។ សំគាល់នូវមគ្គត្រឹមត្រូវ
បានហើយ ព្រះយោគាវចរចាប់ពិចារណាអំពីការកើតនិងការរលត់នៃ
សំខារ (១ ឧទយព្វយញ្ញាណ) បណ្តាការកើតនិងការរលត់ទាំង ២
នេះ ចំណែកខាងរលត់ជាក់ច្បាស់ដល់ចិត្តរបស់លោកជាខ្លាំង ព្រោះឃើញ
ការប្រែប្រួលច្បាស់ជាងការតាំងទៅ ។ ដូច្នេះលោកផ្ចង់ចិត្តទៅកាន់ការ
ពិចារណានូវការបែកធ្លាយនៃសំខារ (២ វយញ្ញាណ) ទើបលោក
ឃើញច្បាស់ថាការប្រេះធ្លាយនៃសំខារជាការគួរខ្លាច (៣ ភគ្គិញ្ញាណ) ។
លោកទាំងមូលប្រាកដដល់ព្រះយោគាវចរ បីដូចជាអណ្តូងពេញទៅ
ដោយភ្លក់ភ្លើង ជាប្រកតប្រកបដោយភ័យ (៤ ភយញ្ញាណ) ។
តទៅព្រះយោគាវចរ រំពឹងគិតពីសភាពទុព្វលភាពនៃលោកកំណាច
សាហាវ គួរខ្លាច (៥ អាទីនវញ្ញាណ) លោកក៏នឿយណាយពីសំខារ
(៦ និព្វិទាញ្ញាណ) មានបំណងនឹងដោះខ្លួនឲ្យផុត (៧ មុញ្ចិតុកម្យតា-
ញ្ញាណ) ។ មានបំណងដូច្នេះ លោកពិចារណានូវត្រៃលក្ខណៈ
តទៅទៀត (៨ បដិសំខារញ្ញាណ) ហើយព្រងើយកន្តើយនឹង

សំខារ ដែលមានការជាប់ជំពាក់ប្រែប្រួលក្នុងវត្ថុឯណាមួយក្នុងលោកនេះ (៩ សំខារុបេក្ខាញាណ) ។

កាលញាណនោះចាស់ក្លាហើយ ក៏ក្លាយជាញាណសំរបអនុលោម (អនុលោមញាណ) អ្នកចំរើនកម្មដ្ឋានក៏ប្រកបដោយចិត្ត នឹងនិស្ស័យសំរបមគ្គ ។ ញាណទាំង ៩ ខាងលើនេះហៅរួមថា បដិបទាញាណទស្សនវិសុទ្ធិ, គឺជាវិសុទ្ធិទី ៦ ។ លុះដល់ការហ្វឹកហ្វឺនចិត្តត្រឹមនេះ ព្រះយោគាវចរទាញយកនូវលក្ខណៈឯណាមួយ ដែលជាទីពេញចិត្តមកធ្វើជាអារម្មណ៍ ហើយចំរើននូវវិបស្សនាញាណក្នុងផ្នែកជាពិសេសនេះយ៉ាងខ្លាំង ត្រាតែបានសម្រេចដល់ព្រះនិព្វានជាដើមដម្បូងក្នុងជីវិតរបស់លោក ពេលនោះលោកបានឈ្មោះថា សោតាបន្ន ។

វីថិចិត្តដែលលោកពិសោធនោះ ដូច្នេះ គឺ ១- បរិកម្ម; ២- ឧបចារ; ៣- អនុលោម; ៤- គោត្រភូ; ៥- មគ្គ; ៦- ផល; ៧- ផល ។

សន្តានចិត្តជាលោកុត្តរដែលនៅក្នុងមគ្គវីថិនោះ កាន់តែវិសេសឡើងៗ តាមថ្នាក់រហូតដល់បាននូវញាណដ៏ប្រពៃ ឈ្មោះថាញាណទស្សនវិសុទ្ធិ ជាវិសុទ្ធិទី ៧ ។ អង្គ ៨ នៃមគ្គដែលពោលដោយខ្លីគឺ ចិត្ត ៨ ប្រភេទស្ថិតក្នុងមគ្គវីថិនោះ ។ សោតាបន្ន ចំរើននូវវិបស្សនាខ្លាំងក្លាឡើងបានសំរេចជាលំដាប់នូវសកទាគាមិ អនាគាមិ នឹងអរហត្តជាទីបំផុត ។

កិត្តិនារេ៖

# អក្សរសាស្ត្រជាពន្លឺជាតិ · ជាគោលបវរកជាតិ
# អក្សរសាស្ត្ររលត់ ជាតិរលត់ ។

## ប្រវត្តិព្រះវិភទ្ញាណសោម-ឡុច

(ដកស្រង់ពីប្រវត្តិដែលលោកស្រី-គ្វី បានរៀបរៀងចុះក្នុងទស្សនាវដ្ដី ម្ពុជសុរិយាឆ្នាំ ១៩៤៨)

ព្រះវិភទ្ញាណ សោម-ឡុប បិតានាម-សោម មាតានាមម៉ុម កើតថ្ងៃអាទិត្យ ៥ កើតខែពិសាខ ឆ្នាំខាលទោស័ក ព.ស. ២៤៣២ ត្រូវនឹងថ្ងៃ ១៨ ឧសភា ឆ្នាំ ១៨៨៩ នៅភូមិក្រាំងគោក ឃុំកក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ កាលអាយុ ១០ ឆ្នាំបានទៅសិក្សាអក្សរខ្មែរ ក្នុងសំណាក់លោកគ្រូសូត្រអុំ វត្តកាត់ក្ដក ឃុំផុង ដល់អាយុ ១៤ ឆ្នាំ បានបព្វជ្ជាជាសាមណេរ រួចហើយបានចេញទៅរៀនបរិយត្តិធម៌ក្នុងសំណាក់លោកអាចារ្យ ណុប ក្នុងវត្តត្រពាំងក្រពើ ឃុំព្រះនិព្វាន ។ អាយុ ២២ ឆ្នាំ បានបំពេញឧបសម្បទាជាភិក្ខុក្នុងពទ្ធសីមាវត្តកាត់ក្ដក បាននាមឆាយាជាសទ្ទម្មលិខិត ។ ភិក្ខុ សោម-ឡុប នៅក្នុងសំណាក់ព្រះឧបជ្ឈាយ៍បាន ១ វស្សាក៏ទៅនៅវត្តស៊ីធរ ឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល រៀនបរិយត្តិធម៌ក្នុងសំណាក់សម្ដេចព្រះធម្មលិខិតឧត្តម-ប្រឹក្សា ល្វី-ឯម គណមហានិកាយ កាលធ្វើជាចៅអធិការវត្តនោះ ។ តមកទៀតបានមកនៅវត្តកែវព្រះភ្លើង ក្រុងភ្នំពេញ រៀនបរិយត្តិធម៌

បានចូលប្រឡងដេញប្រយោគ ក្នុងវត្តព្រះកែវមរកតក្រុងភ្នំពេញជាប់ទី មហា ៤ ប្រយោគក្នុង ព.ស. ២៤៥៧ ។ កាលសម្ដេចព្រះធម្មលិខិត ចេញពីវត្តស៊ីធរមកធ្វើជាចៅអធិការវត្តលង្កាក្រុងភ្នំពេញ ព្រះមហាសោម-ឡុប ក៏ចេញពីវត្តកែវព្រះភ្លើង មកនៅក្នុងវត្តលង្កា បានបង្រៀនព្រះបរិយត្តិធម៌ដល់ភិក្ខុសាមណេរក្នុងវត្តលង្កា តមកសម្ដេចបានចាត់ឲ្យទៅបង្រៀនព្រះបរិយត្តិធម៌ នៅវត្តពោធិ៍ ស្រុកមោងឬស្សី ខែត្របាត់ដំបង អស់ ២ ឆ្នាំទើបត្រឡប់មកនៅវត្តលង្កាវិញ ។

ក្នុង គ.ស. ១៩៣០ ព្រះមហាសោម-ឡុប បានចូលធ្វើជាក្រុមជំនុំប្រែព្រះត្រៃបិដកក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ។

ក្នុងឆ្នាំ ១៩៤៤ បានទទួលសមណស័ក្តិជាទីព្រះគ្រូមុនីសោភ័ណ ហើយក្នុងឆ្នាំដដែលនោះ លោកបានទទួលសមណស័ក្តិជាព្រះវិន័យធម្មទៀត ។

ក្នុងឆ្នាំម្សាញ់ត្រីស័ក ព.ស. ២៤៨៤ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានព្រះរាជទានគ្រឿងឥស្សរិយយសសមណាភរណ ។

ក្នុងឆ្នាំចអដ្ឋស័ក ព.ស. ២៤៨៩ លោកបានទទួលសមណស័ក្តិជាព្រះធម្មមុនីទីពជាគណៈជាន់ចត្វា, ដល់មកថ្ងៃ ៩ តុលា ១៩៤៧ បានឡើងជាព្រះវិកទញ្ញាណទីពជាគណៈជាន់ចត្វាដដែល ។

ព្រះវិកទញ្ញាណ សោម-ឡុប ជាសមាជិក ១ រូបនៃក្រុមជំនុំព្រះត្រៃបិដក លោកមានសមត្ថភាពគ្រប់គ្រាន់ក្នុងមុខក្រសួងរបស់ខ្លួនហើយ

ជាអ្នកយកចិត្តទុកដាក់ផ្ចិតផ្ចង់ធ្វើការងារ ។ ដល់មកថ្ងៃ ១ មីនា (មារ្ស) ១៩៤៨ ស្រាប់តែចាប់មានអាពាធជាទម្ងន់ហួសវិស័យពេទ្យនឹងព្យាបាលបាន, ដល់ថ្ងៃពុធ ៨ កើតខែផល្គុន ឆ្នាំកុរទេព្វស័ក ព.ស. ២៤៩០ ត្រូវនឹងថ្ងៃ ១៨ មីនា ១៩៤៨ វេលាម៉ោង ១៧ លោកក៏ទទួលអនិច្ចធម្ម នៅមន្ទីរពេទ្យព្រះកេតុមាលា ក្នុំពេញក្នុងជន្មាយុគំរប់ ៥៨ ឆ្នាំ ។

ឯស្នាដៃរបស់លោក ជាពាក្យកាព្យក៏មាន ជាពាក្យរាយក៏មាន; ដែលយើងបានស្រាវជ្រាវឃើញ គឺ: អនិមិត្តកធម៌; ព្រះត្រៃលក្ខណ៍នឹងសង្វេគវត្ត, វេរប្បតិវេរកថា, មធុរភាសិត, នានាភាសិត, ។

## ខ្លួនចាស់ចិត្តក្មេង

អ្នកខ្លះខ្លួនចាស់ចិត្តនៅក្មេង    នរណាពោលលេងថាមើលងាយ
គេហៅថា តា-តា យាយ-យាយ    មុខគ្មានរីករាយសប្បាយម្តង ។
កាលបើគេហៅបបឡកឡាយ    ចង់ឲ្យស្រស់ស្រាយស្រួលចិត្តផង
គេហៅថានាង ឬ អ្នកបង    អរក្រៃកន្លងឥតឧបមា ។
ចាស់នេះហៅពេញជាថយថោក    ចាស់គ្មានប្រយោគរូបអាត្មា
ចាស់នេះមិនស្គាល់រូបអនិច្ចា    ចាស់នៅហ៊ឺហាសប្បាយចិត្ត ។

(ដកស្រង់ពីព្រះត្រៃលក្ខណ៍នឹងសង្វេគវត្ត)

ក្បួនមេកាព្យ (តនិងបំ)

## ២២ – កង្កែបលោតលើគោក (ពាក្យ ៤)




រីឯកែវកេតុកែវកាញ់ មនោអាក់ម្នាក់អញម្នេញអួល

គោះខ្វាញ់គេញខ្វោះគោះខ្ជល់ ហៀរអួលហួលឯងហែងអង្គ ៗ

## ២៣ – កង្កែបពេកតស្លាក់ពេជ្រ



វៀមនេះតែងតែងនិកតន់កន់ណាស់ទៅ សែនទុក្ខត្រាំសាំទាំងក្រៅ

សៅសព្វត្រា

វិះមុង្គហ៊ឹងវីងម្ដេចហាកែម្ដងក៏ តែកែងគេថាត្រាកាលថយក្រោយគិតធុញ ៗ

## ២៤ – កង្កែបផ្លាតខ្មៅ



នុម្ពងនេះអេះម្ពងហ៊ានុជួងឆោម កែវមិនប្រែកែមិនព្រមប្ដូរមនោ

បងនេះគិតបិតនាងគេបង្ក្រែវៀបទៅ ដោយចិត្តពាលដាលចង់ពៅនៅ

សព្វថ្ងៃ ៗ

## ២៥ – អក្សរសង្វាស



ព្យុះទេគេទៅប្រាប់ដំណឹងហ្នឹង ហេតុតែអ៊ូស្រែខឹងកំហោកហោក
អាណាថាអ៊ូឲ្យស្អកសោកម៉ោក ប្ដីពេកកម្ហឹងទទេទេ ៗ

## ២៦ – រមាំងដើរព្រៃ



ស្ដាយអើយនួនសួនចិត្តឥតហ្មហ្មង កម្មអើយបងនាំប្រាសទិពសគន់
មនោអើយម្នេញពេញសង្វេគវិវេគលន់ ទុក្ខអើយធ្ងន់ធន់មិនបានរំពន់ស៊ិន ៗ

## ២៧ – ក្របបក្រវាល



ចិត្តវៀមរក្សស្ម័គ្រនួនសួនត្រូវចិត្ត ទៅពិនិត្យគិតសង្វាសនេះណាស់ទៅ
ពៅពុំស្ម័គ្រសោះទេប្អូនមេពៅ បងនេះនៅសង្កាណាមាសបង ៗ

## ២៨ – សារបីទាញរបី



សារស្រែងរែងទ្រូងតឹងរែងសារស្រែង មិនសុខសៃសែនរកាំសាំមិនសុខ
ជាទុក្ខនៅសៅវិយោគសោកជាទុក្ខ មិនក្សាន្តឡើយពីមុខទុក្ខមិនក្សាន្ត ៗ

## ២៩ – ព្រះបត្រូបុំងផ័ត្រ



ត្រៃលក្ខណ៍យោគយោគមិនដល់ត្រៃលក្ខណ៍ ទុក្ខំដោតូដោតបាកពេគទុក្ខំ

ពគពាំងពេលពេលរលាកពេគពគរាំង ប្រាជ្ញាតាំងតាំងកាត់គាស់អស់ប្រាជ្ញា ។

## ៣០ – សឡាបល្លូន



ញាប់ញ័រញាក់ញាក់អន់អួលក្ដួលក្ដៅក្ដាត់

ក្តឹកក្តាំងក្ដាត់ស្លាត់ស្ងប់ស្ងួតហួតហែកហែង

នៅទីងណែនសែនសោកសល់ខ្វល់ខ្វាយខ្វែង

ប្រាណប្រឹងប្រែងរឹងរំខាត់កាត់កាមក្ដួន ។

## ៣១ – វិរិធមាលី

ឃ្លាទី ១ នឹងទី ៣ មាន ៩ ពាក្យ ឃ្លាទី ២ នឹងទី ៤ មាន ៧ ពាក្យ ។ វិធីចួន ពាក្យទី ៧ ក្នុងឃ្លាទី ១ ត្រូវចួននឹងពាក្យទី ២១ ក្នុងឃ្លាទី ៣ ពាក្យទី ១៦ ក្នុងឃ្លាទី ២ ចួននឹងពាក្យទី ៣០ ក្នុងឃ្លាទី ៤ ពាក្យទី ១៤ ក្នុងគាព្យគទៅត្រូវចួននឹងពាក្យទី ៣២ ក្នុងគាព្យខាងដើម ។



បែបតែងធៀប

ឱប្អូនអើយបងរលឹកនឹកអ្នកណាស់ ម្តេចក៏អ្នកបាត់បង់ទៅណា
រៀមគេពេញសង្ខឹកបាត់សុងសូន្យឈឹង ឱស្ងួនរមិត្រក្លាមាសបង ។
ឱនរណា ហ្ន៎ គេទៅថាដូចម្តេច បានជាខុសសព្វដងណាពៅ
បានជាបាត់ពុំងាមិនបានមករករៀម ប្អូនមួយស្ងួនឆោមឆ្លៅគាប់ចិត្ត ។
ឱកែវពិសីបងបងនឹកនាងហើយ ដូចម្តេចឡើយរមិត្តព្រលឹង
រៀមកើតទុក្ខរកសង្ខឹកសង្ខៃ ផ្អែតថ្ពល់ទុកតែងពេកណាស់ ។

## ៣២ – វង្សវិចិត្រ

កាព្យនេះក្នុង ១ ឃ្លាមាន ១០ ពាក្យ ពាក្យទី ១០ ចួននឹងពាក្យទី ១៤ ពាក្យទី ២០ នឹងទី ៣០ ហើយនឹងទី ៣៤ លំនាំដូច្នេះ



បែបតែងធៀប

ថ្ងៃអើយថ្ងៃថ្មើមជាឆ្នើមស្រីកម្ពុជា
អាណិតរៀមក៏អ្នកស្វែងស្ងួនលះបានចិត
តាមរកគូព្រេងវេងក្នាពអតីត
ជួបហើយរមិត្រកុំគិតកែប្រែដោះដៃ ។

ទ្រង់អើយទ្រង់ស្មុតឆើតឆាយកាយត្រចះ
បងបានប្រទះព្រលឹងមិត្តរិតអាល័យ
ខ្វល់ចិត្តរលឹកនឹកកុំភ្លងដួងដកម៉ែ
អាថាអាថៃឌុកការឹងថែមចប់ ។

## ៣៣ – សហាវ

ក្នុង ១ ឃ្លាមាន ១១ ពាក្យ ពាក្យទី ១១ ចួននឹងពាក្យទី ១៦ ពាក្យទី ២២ នឹង ៣៣ ហើយនឹង៣៩ លំនាំដូច្នេះ



បែបតែងធៀប

ឆោមអើយឆោមឆើតកើតក្នុងបុរីកម្ពុជា
រៀមបានឃើញស្ងួនភ្ញាសែនស្រឡាញ់ពេញបេតី
នៅមិនទឹងរឹងអាឡោះអាល័យកែវពិសី
បានជាប្រឹងតែងសេចក្តីផ្ញើមកស្ងួនពុំងា ។
នែកែវគូបុពណាបានរួមគ្នាជាសែនកប្ប
កុំកែវងាកក្រឡាប់កែគំនិតគិតវេក
សូមអាណិតចិត្តរៀមទៅណាពៅពុំងា
បំណាច់បងលេលាយាត្រាមកស្វែងរកស្ងួន ។

## សេចក្ដីសង្ខេបខ្លះៗ អំពីរបៀបគ្រោងផែនការ

យើងបានដឹងមកហើយថាការនិពន្ធ គឺជាការស្ថាបនា, ធម្មតាការសង់តាំងឡាយគេតែងធ្វើឡើងតាមផែនការ ដែលបានគ្រោងហើយដោយហ្មត់ចត់ឲ្យសមរម្យតាមទីដែលសង់ តាមបដិភាគនៃល្បែងនានា ក៏ឯការនិពន្ធត្រូវរៀបផែនការដោយផ្ចិតផ្ចង់ដូច្នោះដែរ យើងនឹងល្បងពិចា-រណាអំពីរបៀបធ្វើផែនការឲ្យបានពិស្ដារបន្តិច តែយើងកុំភ្លេចថាផែនការនេះ គេអាចរៀបចំបានជាច្រើនបែបទៅតាមសេចក្ដីចូលចិត្ត តាមដំណើររឿងតាមប្រភេទរឿងជាដើម; បែបដែលនឹងលើកយកមកពណ៌នាតទៅនេះ សំរាប់តែអធិប្បាយពន្យល់ ឬ ពិចារណានូវកាសិតប៉ុណ្ណោះ ទុកជាបែបសំរាប់រៀនធ្វើផែនការ ។

កាលយើងត្រូវការអធិប្បាយពីកាសិតណាមួយ យើងតោងជញ្ជឹងគិតនូវកាសិតនោះនាពេលស្ងាត់ ឬ ពេលដើរចង្ក្រម កាលលេចគំនិតផុះចេញឡើងកាលណា យើងត្រូវកត់ត្រាគំនិតនោះទុក ដោយមិនចាំបាច់ប្រិតប្រៀបខាងពាក្យពេចន៍តាមលំដាប់ទាក់ទងគ្នាទេ ព្រោះគំណត់តាំងនោះសំរាប់តែជាជំនួយដល់សតិរបស់យើងប៉ុណ្ណោះ ។ បើយើងជាអ្នកសន្សំឯកសារមានកំណត់ចាត់ទុកជារបៀបដូចបានសារស័ព្ទពីលើកមុនមកហើយនោះ នឹងបានជាឧបករណ៍ដ៏សំខាន់មួយក្នុងកិច្ចការរបស់យើង ព្រោះនឹងបានដឹងថារឿងដែលយើងត្រូវរៀបរៀងនោះ មានគេនិយាយ

មកដូចម្ដេចខ្លះ មាន ១ គួរពិចារណាដូចម្ដេចខ្លះ រួចត្រិះរិះពិចារណានូវ ភាសិតនោះឲ្យអស់ជើង ។

កំណត់ទាំងនេះ ទុកដូចជាសម្ភារៈសំរាប់សង់ផ្ទះ គឺឲ្យយើងដឹងថា ផ្ទះយើងនឹងធ្វើពីឥដ្ឋ ក្រាលក្ដារ ប្រក់ក្បឿងជាដើម, តពីនេះទៅ យើងគោងរៀបជារបៀបឲ្យដឹងថានឹងធ្វើផ្ទាំងបែបដូចម្ដេច ល្វែងប៉ុនណា ទទឹងបណ្ដោយកំពស់ - សណ្ឋានជាដើម តាមកំណត់ដែលបានដែលទុកមក · គឺរៀបផែនការនោះឯង ។

ផែនការទាំងឡាយគេតែងចែកជា ៣ ផ្នែក ខាងដើម (លំនាំដើម) កណ្ដាល (សេចក្ដីអធិប្បាយ ឬ សេចក្ដីដោះស្រាយ) ខាងចុង (សេចក្ដីបញ្ចប់ ឬ ការចុះមតិ) យើងនឹងពិចារណាពីគោលការណ៍សំខាន់ៗ នៃផ្នែកទាំង ៣ ជាមុន ។

លោកអារីស្តូតអ្នកប្រាជ្ញបរមត្ថមានកេរ្តិ៍ឈ្មោះជាតិក្រិក បានពន្យល់ថា "ផ្នែកដើម គឺផ្នែកដែលពុំចង់ឲ្យមានអ្វីពីមុនមកហើយចង់ឲ្យមានអ្វីតទៅទៀត ។

ផ្នែកកណ្ដាលគឺផ្នែកដែលចង់ឲ្យមានអ្វីពីមុនមកហើយចង់ឲ្យមានអ្វីតទៅទៀត ។

ផ្នែកខាងចុងគឺផ្នែកដែលចង់ឲ្យមានអ្វីពីមុនមកហើយមិនចង់ឲ្យមានអ្វីតទៅទៀត" ។

# ក – ផ្នែកដើម

ជាដម្បូងគេបានប្រាប់ឲ្យគេដឹងថាតើយើងត្រូវការនិយាយពីអ្វី ដោយហេតុអ្វីបានជានិយាយរឿងនោះ ឬក៏មានវត្ថុបំណងដូចម្តេច ដើម្បីឲ្យអ្នកអានអាចទទួលចាប់សាច់រឿងបាន ដឹងប្រយោជន៍ ឬ លំនាំនៃរឿងនោះ ដោយគ្រាន់តែបានមើលពីរបីបន្ទាត់ខាងដើមនោះ ប្រសិនបើគេមិនដឹងថាយើងចង់ថាអ្វីទេ គេក៏នឹងមិនចូលចិត្តមើលសេចក្តីរបស់យើងដែរ ។

គ្មានអ្វីពីមុន.– តើធ្វើលំនាំដូចម្តេចកុំឲ្យអ្នកអានគេសង្ស័យសាកសួរខ្លួនគេថា ចុះអ្នកតែងចង់និយាយពីរឿងអ្វី មានអ្វីពីមុនមក ដូចយើងចូលទៅស្តាប់គេកំពុងនិយាយគ្នា ហើយមិនដឹងរឿងដែលគេនិយាយពីពេលមុនយើងទៅដល់នោះ នាំឲ្យតែយើងគិតឆ្ងល់ចង់ដឹងថា តើគេនិយាយអ្វីខ្លះមកហើយ ។

មានអ្វីតទៅទៀត.– បើក្នុងលំនាំដើមយើងញែកសេចក្តីអស់ទៅហើយ លំនាំដើមនឹងទៅជាសេចក្តីបញ្ចប់ ពុំបានឈ្មោះថាលំនាំដើមទេ ដូច្នេះក្នុងលំនាំដើម យើងត្រូវនាំអ្នកអានឲ្យដឹងថានិយាយពីអ្វី ហើយចង់និយាយដូចម្តេច ដោយពុំទាន់និយាយឲ្យដឹងអស់ទៅឡើយ គ្រាន់តែបញ្ចេញចិត្តឲ្យចង់ដឹង ឲ្យចង់អានតទៅ តែត្រូវនាំឲ្យច្បាស់លាស់ ។

ដូច្នេះ លំនាំដើមត្រូវមានកម្រិតនឹងនាំអ្នកអានឲ្យដឹងរឿងដែលយើងត្រូវនិយាយ នឹងតាំងតួប្រស្នា ឬតួរឿងដោយច្បាស់លាស់ ជួនក៏ប្រាប់ខដែលត្រូវពិចារណា ឬអធិប្បាយក្នុងរាយសេចក្តីតទៅ ។

តែលំនាំដើមនេះ តោងឲ្យខ្លីល្មមកុំឲ្យលុបលើសភាគដទៃ ; លំនាំដើមនេះពិបាកនឹងធ្វើឲ្យបានសមក្នុងការនិពន្ធ គប្បីពិនិត្យឲ្យហ្មត់ចត់ ។

កំហុសដែលត្រូវចៀសវាងនោះ គឺកុំប្រើលំនាំសាមញ្ញ ដែលអាចប្រើសាធារណ៍គ្រប់រឿងបាន ដូចជាចង់អធិប្បាយពីភាសិតណាមួយ ចាប់និយាយពីគុណសម្បត្តិ ឬលក្ខណៈនៃភាសិតទាំងឡាយថាជាក់ចា មិនស្លាប់មានរសជាតិឆ្ងាញ់ពីសាជាដើម ឬចង់ពន្យល់ធម៌ណាមួយ នោះត្រូវកុំផ្តើមអធិប្បាយពីផ្លូវទៅកាន់សេចក្តីសុខចៀសវាងទុក្ខ មានខុសមានត្រូវជាដើម ព្រោះជាលំនាំសាប់លាបមិនចំពោះផ្ទាល់រឿងដែលត្រូវនិយាយ ។

## ១ – ផ្នែកកណ្តាល

ផ្នែកនេះជាផ្នែកនៅចន្លោះ ផ្នែកដើមនឹងផ្នែកចុង បើតាមលោកអារិស្តូត គឺថា :

មានអ្វីពីមុនមក = ផ្នែកនេះនឹងអាចយល់បាន ដោយសារមានលំនាំដើមរៀបចំនាំឲ្យដឹង បើគ្មានលំនាំពីដើមមកទេ មិនអាចនឹងចាប់សេចក្តីបានឡើយ ។

មានអ្វីតទៅទៀត = បើគ្មានអ្វីតទៅទៀត ផ្នែកនេះនៅមិនទាន់ចប់សព្វគ្រប់ អ្នកអានពុំទាន់អស់ចិត្ត នៅចង់ដឹងតទៅទៀត ដូចទៅមើលល្ខោនដែលរ៉ាកេងហើយ នៅពុំទាន់ចប់រឿង ។

តែថាផ្នែកកណ្ដាលនេះ គោងនាំមកនូវសេចក្ដីបញ្ចប់ ដោយពុំទាន់បញ្ចប់នៅឡើយ ដូចគ្នានឹងលំនាំដើមនាំមកនូវផ្នែកកណ្ដាលដូច្នេះឯង រៀបរាប់ដូចម្ដេចឲ្យទាល់តែឃ្លាចុងក្រោយនៃផ្នែកកណ្ដាលនេះ បង្គាប់ឲ្យមានសេចក្ដីបញ្ចប់ដោយខានពុំបាន គេតែងប្រៀបទៅនឹងកន្ត្រងចាក់ប្រេងដែលមានរង្វង់ធំខាងលើ ហើយស្ដួចទៅខាងចុង គឺឲ្យប្រេងរត់ចូលក្នុងរន្ធតែមួយ ធ្លាក់ចុះក្នុងដប ។

ភាពនៃផែនការមាន ៣ ថ្នាក់ គឺ លំនាំដើម, ផ្នែកកណ្ដាលនិងសេចក្ដីបញ្ចប់ បើគំនិតដែលត្រូវអធិប្បាយ ជាភាសិតណាមួយ មានការបញ្ជាក់តែមួយផ្លូវ ដូចជាការអធិប្បាយអំពីការចោទប្រកាន់ព្រះពុទ្ធៈសាសនាថាជាសាសនានៃសេចក្ដីទុក្ខ (ទុទិដ្ឋិ) យើងអាចរៀបផែនការបែបដូចតទៅនេះ ។

**លំនាំដើម**– គេចោទប្រកាន់ដោយឥតសមហេតុសមផលថាព្រះពុទ្ធសាសនាជាសាសនា ទុទិដ្ឋិ ។

**ផ្នែកកណ្ដាល**– ព្រោះ ឲ្យឧទាហរណ៍ផ្សេងៗ បញ្ជាក់ពីផ្លូវនាំទៅកាន់សេចក្ដីសុខ ។

**សេចក្ដីបញ្ចប់** – ដូច្នេះព្រះពុទ្ធសាសនាពុំមែនជាសាសនាទុទិដ្ឋិទេ ។

ឯការទិទស្សន៍នូវគំនិតនីមួយៗ មានរបៀបប្រើផ្សេងៗគ្នា ដូចជា

**ប្រប័ក្យៈ** ច្បាស់លាស់ដោយចង្អុលហេតុឲ្យឃើញជាឧទាហរណ៍ ឬការ

គាន់ផលសំដីអ្នកប្រាជ្ញ **អនុមានៈ** ទាញសេចក្ដីដោយការពិចារណារកហេតុផលពីសភាវការណ៍ដែលស្គាល់ច្បាស់លាស់ ទៅបញ្ចូលក្នុងសភាវ-ការណ៍ដែលពុំស្គាល់ ឬក៏ទាញមតិពីសភាវការណ៍ទៅបញ្ចូលក្នុងសភាវ-ធម៌ដែលមានប្រភេទដូចគ្នា នឹង **ឧបមា** គ្រឿងប្រៀបធៀបជាដើម ។

ទោះបីប្រើរបៀបបែបណាក៏ដោយ គំនិតនីមួយៗ មិនមែនសុទ្ធតែមានរបៀបងាយដូចបានរៀបផែនការខាងលើនោះទេ, ផ្នែកកណ្ដាលច្រើនតែមានបែកចេញជាភាគចំនួន ២ ឬ ៣ភាគ ឬច្រើនជាងនេះទៅទៀត ព្រោះសេចក្ដីដែលត្រូវអធិប្បាយតែងមានដំណើរផ្សេងៗ គ្មានឹងរួមក្នុងភាគជាមួយគ្នាពុំបាន សេចក្ដីខ្លះជាសេចក្ដីពន្យល់ ខ្លះជាពាក្យកែ ខ្លះជាសេចក្ដីផ្ទុយគ្នានឹងគំនិតដើម ខ្លះទៀតស្របគ្នា ឬមានលំនាំទាក់ទងគ្នា ដូច្នេះត្រូវបែកផ្នែកកណ្ដាលជាភាគតាមដំណើរសេចក្ដី ហើយភ្ជាប់ភាគដើមនឹងភាគបន្ទាប់ឲ្យជាប់ទាក់ទងគ្នា ឲ្យដូចជាគេដាក់ស្ពានឆ្លងស្ទឹងពីត្រើយម្ខាងទៅត្រើយម្ខាងទៀត កុំឲ្យអ្នកអានលោតពីភាគនេះទៅភាគនោះឲ្យសោះ ឯដំណើរសេចក្ដីសោតតោងបាញ់តម្រង់ទៅរកគំនិតដើមជាដរាប កុំឲ្យងាកឃ្លាតពីគំនិតដើមឲ្យសោះ ដូចជាយើងត្រូវការនិយាយពីការសរសើរប្រាសាទអង្គរវត្ត បើជាត្រូវប្រៀបធៀបនឹងប្រាសាទដទៃក្នុងលោកផង ក៏ឲ្យគ្រាន់តែជាការលើកដំកើងប្រាសាទអង្គរ ឲ្យវិសេសឡើងប៉ុណ្ណោះ កុំទៅពណ៌នាពីប្រាសាទដទៃឲ្យហួសហេតុ ព្រោះនឹងនាំឲ្យឃ្វាងពីគំនិតដើមរបស់យើង ។

បើយើងយកគោលការណ៍ដែលបានពោលមកនេះ ទៅពិនិត្យផែនការរឿងព្រះពុទ្ធសាសនាដែលយើងបានធ្វើមកហើយ យើងអាចកែប្រែផែនការនោះ ដោយញែកផ្នែកកណ្ដាលជាភាគដូច្នេះ

១)- ពិតមែនជាព្រះពុទ្ធសាសនាបានប្រដៅថាអ្វីក៏ជាទុក្ខទាំងអស់ក្នុងលោកនេះ ជាសត្វតែងជាប់ក្នុងចំណោមនៃសេចក្ដីទុក្ខគ្រប់រូប ។

២)- តែបង្ហាញឲ្យស្គាល់ទុក្ខដើម្បីឲ្យស្គាល់ផ្លូវទៅរកសេចក្ដីរំលត់ទុក្ខនោះ ។

ចុះមតិ : ដូច្នេះព្រះពុទ្ធសាសនាពុំមែនជាសាសនាទុទិដ្ឋិទេ ។

រៀបផែនការណ៍បែបនេះ ជាការរៀបចំនូវសេចក្ដីបញ្ចប់ឬការចុះមតិ ប្រសិនបើយើងយកខទី ១ មកដាក់ជាខទី ២ វិញ វគ្គនេះមិនបានហុចនូវសេចក្ដីបញ្ចប់មកឲ្យទេ ព្រោះរឿងទុក្ខជារឿងសំខាន់ពេញទី នឹងបញ្ចប់ថាព្រះពុទ្ធសាសនាពុំមែនជាសាសនាទុទិដ្ឋិពុំសមរម្យ ។

## គ - ផ្នែកខាងចុង

យើងបានឃើញមកហើយថា ផ្នែកដើមជាផ្នែកសំរាប់ចងប្រស្នាទាញចិត្តអ្នកអានឲ្យចង់ដឹងរឿងដែលយើងនិពន្ធ ផ្នែកកណ្ដាលជាផ្នែកដោះស្រាយនូវប្រស្នានោះ ដោយអធិប្បាយឲ្យចូលទៅជិតគំនិតដើម ដើម្បីនឹងនាំមកនូវសេចក្ដីបញ្ចប់ឬការចុះមតិ ឥឡូវនេះ យើងត្រូវបញ្ចប់រឿងរបស់យើង ឯការបញ្ចប់នេះ នឹងបញ្ចប់តាមចិត្តពុំបានទេ គោង

បញ្ចប់ទៅតាមគោលការណ៍ដូចលោក គារ៉ស្គូត បានពោលទុកមកហើយ ថាផ្នែកខាងចុង គឺផ្នែកដែលត្រូវការអ្វីពីខាងដើមមក ហើយដែលមិនត្រូវការអ្វីតទៅទៀត ។

មានអ្វីពីខាងដើម ៖— ដូចយើងបានឃើញមកហើយ បើគ្មាននិយាយអ្វីពីដើមមកទេ យើងនឹងបញ្ចប់ពុំកើតទេ ដូចជាយើងមិនអាចសំរេចចុះមតិថា "ដូច្នេះព្រះពុទ្ធសាសនាពុំមែនជាសាសនាទុទិដ្ឋិទេ" ដោយឯកឯងនោះបានឡើយ ព្រោះពុំបានសហេតុផលក៏ឃើញសោះ; ដូច្នេះ ផ្នែកខាងចុងជាផ្នែកសំពប់រួបរួមប្រមូលមតិអំពីរឿងដែលបានពិចារណាឬដោះស្រាយមកហើយ គឺថាមានអ្វីពីមុនមក ។

គ្មានអ្វីតទៅទៀត.— បើមានអ្វីតទៅទៀត នឹងទុកជាផ្នែកខាងចុងដូចម្ដេចបាន? បានសេចក្ដីថា លុះអ្នកអានបានមើលសេចក្ដីចប់សព្វគ្រប់ហើយ ឥតមានត្រូវការចង់ដឹងអ្វីក្រៅពីរឿងនិពន្ធនោះៗ ទៀតទេ ។ ពិតមែនតែចិត្តមនុស្សមានសេចក្ដីត្រូវការជាអនេកប្បការ មិនអាចនឹងបំពេញបានឲ្យបរិបូណ៌សព្វគ្រប់ទេ ហើយពុំមាននរណាមួយអាចនិយាយពីរឿងអ្វីមួយឲ្យបានអស់ដើមនោះទេ តែសេចក្ដីបញ្ចប់គប្បីតែឆ្លើយឲ្យស្របតាមដែលអាចនឹងសព្វបាន នូវសេចក្ដីត្រូវការចង់ដឹងចំពោះរឿងដែលយើងតែងតាមដែលយើងបានតាំងទុកមក ឬ គោលរឿងពីខាងដើមមកនោះ ។

លោកអ្នកប្រាជ្ញខាងការនិពន្ធ បានប្រៀបធៀបការតែងសេចក្ដីទៅនឹងការធ្វើដំណើរ លំនាំដើមចង្អុលនូវផ្លូវត្រូវដើរនឹងសេចក្ដីសង្ឃឹមដែល

ត្រូវតាំងទុកក្នុងចិត្ត, ផ្នែកកណ្តាលជាដំណើរទៅតាមផ្លូវនោះ ផ្នែកខាងចុង គឺការធ្វើដំណើរចប់ហើយ ដំណើរនោះបានធ្វើដោយគ្រប់គ្រាន់ដល់សេចក្តីសង្ឃឹមដែលបានតាំងទុកនាពេលចេញដំណើរទៅ ឬក៏លោកប្រៀបនឹងផ្លូវវង់មូល ចេះដើរចប់ហើយមិនដល់ចំណុចដើមទេ គឺនៅតែខ្វះខាតអ្វីទៀត, អ្នកមានទៅតែពុំទាន់អស់ចិត្តទៅឡើយ ។ បើវិលមកកាន់ចំណុចដើមវិញ ទើបទុកជាសេចក្តីបញ្ចប់បានមែន. សេចក្តីបញ្ចប់ដែលគ្មានត្រូវការអ្វីតទៅទៀត ។

សូម្បីបើសេចក្តីបញ្ចប់ ជាការវិលមករកផ្នែកដើមវិញក៏ដោយ សេចក្តីបញ្ចប់នោះ នៅតែប្លែកពីផ្នែកដើមជាដរាប ព្រោះពេលដែលចេញទៅ គ្រាន់តែដឹងផ្លូវដើរ ដើរទៅរកអ្វី លុះវិលមកវិញបានឃើញផ្លូវនោះសព្វគ្រប់ព្រមទាំងសម្គាល់ដែលជួបប្រទះតាមផ្លូវនោះ នឹងបាននូវអ្វីដែលយើងសង្ឃឹមនោះមកផង ។

របៀបដែលយើងបានពិចារណាមកខាងលើនេះ គ្រាន់តែជារបៀបសំរាប់ហ្វឹកហាត់ធ្វើផែនការប៉ុណ្ណោះ តែផ្នែកនីមួយៗតែងជាប់ទាក់ទងគ្នាជាធ្លុងមួយ គេតែងពិនិត្យតាមគ្រោងផែនការទាំងមូល មុននឹងសំរេចយកផ្នែកនីមួយៗជាការដាច់ខាត, លំដាប់ពីរៀបផែនការទៅ យើងអាចចាប់និពន្ធរឿងបានតាមពេលដែលទំនេរ ដោយមិនខ្វាចដាច់ក្រែសគំនិត ព្រោះដំណើររឿងដែលយើងត្រូវធ្វើនោះ យើងបានរៀបរយគោលទុកជាមុនរួចស្រេចហើយ ។

សុភមិត្ត

## បញ្ចតន្ត្រៈ (តមក)

សញ្ជីវកៈ និយាយតបថាៈ "នែសំឡាញ់ដ៏ចំរើន! សំឡាញ់និយាយនេះត្រឹមត្រូវហើយ បើដូច្នោះ សំឡាញ់និយាយហើយយ៉ាងណា ខ្ញុំនឹងធ្វើតាមយ៉ាងនោះ' ។ កាលសញ្ជីវកៈ និយាយព្រមតាមយ៉ាងនេះហើយ ចចកទមនកៈ ក៏នាំសញ្ជីវកៈទៅកាន់សំណាក់បិង្គលកៈ ដល់ហើយនិយាយជំរាបថាៈ "បពិត្រទេវបាទ! ខ្ញុំបាទនាំគោឧសភសញ្ជីវកៈ ចូលមកជូនលោកម្ចាស់ សូមលោកម្ចាស់ទទួលហើយប្រើប្រាស់តាមការគួរចុះ" ។ ឯគោសញ្ជីវកៈ ប្រណម្យបិង្គលកៈ ដោយគោរពដ៏ក្រៃលែង ហើយឋិតនៅក្នុងទីចំពោះមុខតាមទំនៀម ។ បិង្គលកៈ ដាក់ជើងមុខខាងស្តាំដ៏ប្រដាប់ដោយក្រចកមុតដូចប៉ូវថៅពេជ្រទៅលើសញ្ជីវកៈ ដែលមានបូកធំក្រាស់ ហើយនិយាយសំណេះសំណាលដោយសេចក្ដីរាប់អានថា "សញ្ជីវកៈ! ម្ដេចទៅ ឯងសុខសប្បាយក្សេមក្សាន្តទេឬអ្វី? ចុះឯងមកពីឋានណា មកនៅក្នុងព្រៃទុរគមដ៏ធំស្ងាត់ឥតមានមនុស្សដូច្នេះ?" ។ សញ្ជីវកៈរៀបរាប់ប្រវត្តិហេតុខ្លួនប្រាប់តាមដំណើរដើមទងតាំងពីសេដ្ឋីវឌ្ឍមានៈ លះបង់ចោលរហូតមកដល់ឥឡូវនេះ ។ បិង្គលកៈ លុះបានស្ដាប់ប្រវត្តិហេតុដូច្នេះហើយ មានចិត្តអាណិតអាសូរនិយាយបបាកអាភក សាទរដ៏ក្រៃលែងថាៈ "សំឡាញ់! ឯងកុំភ័យខ្លាចអ្វី, ចូរនៅតាមសេចក្ដីពេញចិត្តក្នុងព្រៃនេះចុះ ព្រោះឯងត្រូវយើងគ្រប់គ្រងរក្សាទុកក្នុងទ្រង

គ្របគ្រងយើងហើយ មួយទៀតចូរឯងនៅជិតយើងអស់កាលជានិច្ច ព្រោះព្រៃនេះប្រកបដោយភ័យច្រើនប្រការ ដែលកើតពីសត្វសាហាវយង់ឃ្នងទាំងឡាយ មិនមែនជាទីនៅអាស្រ័យនៃសត្វធំៗ ហើយមានស្មៅជាអាហារដូចឯងទេ" ។ បិណ្ឌលកៈ និយាយប្រាប់សត្វគ្រប់ប្រការហើយក៏ចុះទៅកាន់ទន្លេយមុនាព្រមមួយអន្លើដោយបរិវារ ផឹកទឹកមុជទឹកតាមសេចក្ដីប្រាថ្នា ហើយត្រឡប់មកកាន់ព្រៃទីលំនៅខ្លួនវិញ ដោយសេចក្ដីក្សេមក្សាន្ត ។ លំដាប់នោះបិណ្ឌលកៈ តាំងទមនកៈ និងករដកៈជាអគ្គមហាសេនាឲ្យទទួលភារៈកិច្ចការផែនទឹកផែនដី ខ្លួនឯងសោយសេចក្ដីសុខក្នុងការប្រជុំពោលសុភាសិតផ្សេងៗ ជាមួយគោសញ្ជីវកៈ ដោយសេចក្ដីសប្បាយ, ព្រោះថាៈ–

១៥១ – សេពគប់សប្បុរសអស់វារៈតែម្ដង ក៏ទន់ទោរជិតដោយសប្បុរសមួយរំពេច ហើយឋិតថេរមាំមួននៅអស់កាលដ៏យូរ មិនបាច់ចាំតែសេពគប់រឿយៗទេ ។

បិណ្ឌលកៈដែលល្ងង់ខ្លៅអប្បឥតប្រាជ្ញា កាលសេពគប់សញ្ជីវកៈត្រឹមតែពីរបីថ្ងៃប៉ុណ្ណោះ ក៏បានទៅជាអ្នកប្រាជ្ញមានពុទ្ធិប្រាកល្ភ[១] ដោយការសិក្សាសាស្ត្រវិជ្ជាទាំងឡាយនានាជាអនេក, និងដោយការហ្វឹកហ្វឺនប្រៀនប្រដៅ ឲ្យលះបង់សភាពជាអរញ្ញធម៌[២] ហើយឲ្យតាំងនៅក្នុងសភាព

---

១ សេចក្ដីពិចារណាត្រឹមត្រូវតាមហេតុផល តាមយុត្តិធម៌ មិនជ្រុលសេចក្ដី ។

២ សភាពជាអ្នកព្រៃ ។

ជាគ្រាមធម៌ (១) ។ តាំងពីកាលនោះមក សត្វទាំងពីរនៅតែគ្នាពីរនាក់ ពួកហ្វូងម្រឹគទាំងឡាយដ៏សេសទាំងពួង មិនហ៊ានចូលទៅអង្គុយជិតបិតនៅតែពីចំងាយ សូម្បីតែសេនាបតីដូចទមនកៈនឹងករដកៈ ក៏មិនបានចូលទៅជិតបិង្គលកៈឡើយ ។ សត្វទាំងអស់ កាលឃើញថាសីហៃលែងប្រើអំណាចពាលសក្តិ លែងប្រកបកិច្ចការដើរបរបាញ់ចាប់ម្រឹគទាំង-ឡាយដូច្នោះហើយ ក៏ធ្លាក់ក្រិក្រអត់បាយក្រហាយទឹក ក៏បបួលគ្នាគេចសខ្លួនគេចរត់ទៅកាន់ទីផ្សេងៗ ទៅ, ព្រោះថា: –

១៥២ – អាមាត្យទាំងឡាយ តែងលះបង់ព្រះនរបតីខ្លួនដែលក្រិក្រឥតទ្រព្យសម្បត្តិចោល សូម្បីព្រះនរបតីអង្គនោះ មានត្រកូលខ្ពស់ នឹងមានអំណាចធំក៏ដោយ ដូចបក្សីទាំងឡាយ លះបង់ចោលដើមឈើទ្រនំខ្លួនដែលឥតសន្ទុកផ្លែផ្កាដូច្នោះ ។

១៥៣ – អាមាត្យ ដែលជាអ្នកមានត្រកូល មានសេចក្តីគោរពមានស្វាមីភក្តិ បើព្រះរាជាលែងចិញ្ចឹមហើយ ក៏បោះបង់រត់ចោលព្រះរាជានោះ ។

១៥៤ – ព្រះរាជាអង្គណា តែងបំប៉នអាមាត្យដោយគ្រឿងចិញ្ចឹមជីវិត តាមកាលមិនឲ្យខុសកាលវេលា អាមាត្យ បើទុកជាព្រះរាជាអង្គនោះជេរគម្រាម ក៏មិនរត់ចោលព្រះរាជាក្នុងកាលណាឡើយ ។

(មានត)

---

១ សភាពជាអ្នកស្រុក ។

IMPRIMERIE ROYALE